

# ដំណាំម្ទេស

## ការរៀបចំដីដាំ

- រៀបចំរងទំហំ១ម៉ែត្រ (ត្រូវមានកំពស់ ៣០ ស.មយ៉ាងតិចនៅរដូវវស្សា)
- ពង្រាយជីលាមកគោស្ងួត រឺជីកំប៉ុស្ដិ៍ និងជីកែងៗពេញរងហើយកាប់ប្រចល់ជាមួយដីអោយសព្វល្អ
- គ្របរងដោយ ចំបើងស.ម បានកំរាស់យ៉ាងតិច ៥សង់ទីម៉ែត្រ រឺប្រើគំរបជីផ្លាស់ស្ទិក ដើម្បីការពារស្មៅចង្រៃ និងរក្សាសំណើមដី



## ការបណ្ដុះកូន:

ដើម្បីបានកូនម្ទេសដែលមានសុខភាពល្អ យើងត្រូវបណ្ដុះកូននិងកន្ទោងតាមរបៀបខាងក្រោម:

- រៀបចំកន្ទោងបណ្ដុះ( ស្លឹកត្នោត រឺស្លឹកចេក )ឬ ថាសបណ្ដុះ
- យកដីមានជីជាតិ( ដីដំបូក ) ១ភាគដីកំប៉ុស្ដិ៍រឺជីលាមក



គោដែលរលួយ១ភាគ និងផេះអង្កាម១ភាគ លាយជាមួយគ្នាហើយយកទៅ លីងអោយក្ដៅបំផុត រួចទុកអោយត្រជាក់ទើបដាក់កន្ទោង។ បើមិនលីងល្បាយដីទេ កូនដំណាំងាយមានជំងឺផ្សិតធ្វើឱ្យលួយបាន។

- បណ្ដុះតែ១គ្រាប់ក្នុងមួយកន្ទោង ត្រូវគ្របសំណាញ់សត្វល្អិត និងធ្វើដំបូលគ្រប្រអំពីស្លឹកដូង រឺ សំណាញ់កាត់ពន្លឺនៅរដូវក្ដៅ ។ និងរដូវវស្សាត្រូវធ្វើដំបូលការពារទឹកភ្លៀង ពីព្រោះកូនដំណាំនៅតូចមិនត្រូវការពន្លឺនិងទឹកច្រើនទេ។
- ស្រោចទឹក១ថ្ងៃ មួយដងនៅពេលព្រឹក( បើទុកដីបណ្ដុះស្ងួត គ្រាប់មិនអាចដុះបានទ បើកូនដុះហើយក៏នៅក្រិនដែរ )

កូនដំណាំមានសុខភាពល្អ ជួយអោយដំណាំធំលឿន កាត់បន្ថយការបំផ្លាញពីជំងឺ សត្វល្អិត និងទទួលទិន្នផលបានស្មើគ្នា



## ការដាំកូនម្ទេស

- ត្រូវដាក់កូនម្ទេសអោយត្រូវពន្លឺថ្ងៃពេញចំនួន២ទៅ ៣ ថ្ងៃមុនដាំដើម្បីអោយដើមរឹងមាំល្អហើយស៊ាំនិងអាកាសធាតុខាងក្រៅ
- កូនម្ទេសអាយុបាន ២៥-២៨ថ្ងៃ អាចយកទៅដាំបាន (អាស្រ័យតាមការថែទាំកូន)
- ស្រោចទឹកកូនម្ទេសអោយសើមនៅពេលព្រឹក ទើបយកូនម្ទេសទៅដាំនៅវេលាពេលរសៀល
- យកកូនចេញពីកន្ទោង ឬថាសបណ្ដុះដោយប្រយ័ត្នបំផុតមិនត្រូវអោយដាច់ឬសកូនម្ទេសឡើយ ព្រោះធ្វើអោយកូនម្ទេសអន់បាននៅពេលដាំ
- ត្រូវស្រោចទឹកកូនម្ទេសអោយបានគ្រប់គ្រាន់បន្ទាប់ពីដាំហើយ ជាពិសេសរវាងពី២-៣ អាទិត្យបន្ទាប់ពីដាំកូនហើយ



## ការថែទាំ

- ត្រូវស្រោចទឹកឲ្យបានគ្រប់គ្រាន់នៅពេលព្រឹកជៀសវាងស្រោចទឹកច្រើនពេកធ្វើអោយដីសើមជ្រុលនៅពេលថ្ងៃល្ងាច វាអាចបង្កអោយមានបញ្ហាដល់ ដំណាំបានបន្ទាប់ពីដាំកូនបាន៧-១៥ថ្ងៃ ត្រូវដោតឈើទំរដែលមានកំពស់៧តឹក ហើយចងដើមម្ទេសទៅនិងឈើទំរដើម្បីទប់ដើមកុំឲ្យដួល យើងអាចបេះបានយូរ។

